**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
No. ០៨៦ MOC / M 2005

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥

# ប្រកាស

## ស្តីពីស្ថានភាពរោងចក្រកាត់ដេរមួយចំនួននៅកម្ពុជា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្របក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្ត ទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១ :** ចាត់ទុកថាបាន **បិទទ្វារជាបណ្តោះអាសន្ន** រោងចក្រកាត់ដេរសំលៀកបំពាក់ខាងក្រោមដែលគ្មានសកម្មភាពចំពោះមុខដោយ មូលហេតុផ្សេងៗ ប៉ុន្តែ ឧបករណ៍ផលិតកម្ម និង គ្រឿងម៉ាស៊ីន បានរើចេញអស់ហើយកម្មករត្រូវ បានបញ្ឈប់ពីការងារជាបណ្តោះអាសន្ន ។

**1- BELGIAN INDUSTRIES CO., LTD.**

**2- LUCKY ZONE APPAREL (CAM) LTD.**

រោងចក្រកាត់ដេរសំលៀកបំពាក់ទាំងនោះនឹងត្រូវលុបចេញពីតារាង GSP នៃអ្នកមានសិទ្ធនាំចេញ នៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។

រោងចក្រខាងលើនេះ អាចទទួលបានសិទ្ធនាំចេញសាជាថ្មីប្រសិនបើរោងចក្រនោះបន្តសកម្មភាពរបស់ខ្លួនវិញក្នុងរយៈពេល ៣ ខែបន្ទាប់ ។

ប្រសិនបើរោងចក្រនោះមិនបានបន្តសកម្មភាពរបស់ ខ្លួនក្នុងរយៈពេល ៣ ខែបន្ទាប់ រោងចក្រទាំងនោះ នឹងត្រូវចាត់ទុកថាបានបិទទ្វារជាស្ថាពរ ។ ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មរបស់គេ នឹងត្រូវឆូតពណ៌ក្រហម និង ចារថាបាន បិទទ្វារ ។

**ប្រការ ២ :** ការស៊ើបអង្កេតបន្ថែមទៀតនឹងត្រូវធ្វើឡើងដោយ នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស, នាយកដ្ឋាននិតិកម្ម ទាក់ទិនបំណុល និង ការទទួលខុសត្រូវផ្សេងៗនៃរោងចក្រដែលមានឈ្មោះខាងលើចំពោះតតីយជននៅកម្ពុជា ព្រមទាំងបំណុលរបស់គេចំពោះច្បាប់ និង បទបញ្ញត្តិកម្ពុជា ។

**ប្រការ ៣ :** អគ្គនាយកបច្ចេកទេស, នាយិកាខុទ្ទកាល័យ, ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស, ប្រធាននាយកដ្ឋាននិតិកម្ម និង រោងចក្រដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**<u>ចម្លងជូន</u> :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ***ស ខេង***
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ***ហោ ណាំហុង***
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងប៉ារីស
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
URL : http://www.moc.gov.kh E-Mail : moccabdir@yahoo.com
Senior Minister's Cabinet Mobile Phones: (855-12) 933 323 / 881 223 Facsimile: (855-23) 426 396 / 213 288 / 991 708